ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៦ សរ

# សារាចរ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និង ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥

## ១-សេចក្តីផ្តើម

១-អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញសារាចរស្តីពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ កាលពីខែ មករា ឆ្នាំ ២០២៤ ដែលក្នុងនោះ បានកំណត់អំពីពេលវេលានៃការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ និង ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ សម្រាប់ជាមូលដ្ឋាននៃការរៀបចំសេចក្តីព្រាងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ជា**សារាចររួមតែមួយ** ដើម្បីដាក់ជូន**នាយករដ្ឋមន្ត្រី** ពិនិត្យ និងសម្រេចនៅដើមខែ ឧសភា។

២-ដោយផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ និង ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ដែលបានកំណត់, សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានដាក់ចេញ ដើម្បីផ្តល់មគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ និងការណែនាំពាក់ព័ន្ធដល់គ្រប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់ការរៀបចំថវិកាពាក់ព័ន្ធនឹងមុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា (៣ ឆ្នាំរំកិល) ឆ្នាំ ២០២៥-២០២៧ និងលើកគម្រោងថវិកាឆ្នាំ ២០២៥។

## ២-ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧

៣-ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ បានផ្តល់ទស្សនវិស័យរយៈពេលមធ្យមនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិ សម្រាប់រយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ក៏ដូចជាផ្តល់នូវលំហថវិការួម សម្រាប់ដោះស្រាយតម្រូវការចំណាយរបស់គ្រប់ក្រសួង-ស្ថាប័នសម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្នុងន័យនេះ,

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម បានកំណត់នូវពិតានថវិកាជាកញ្ចប់រួមជាក់លាក់ ដែលជាលទ្ធភាពថវិការបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ ២០២៥ ជាឆ្នាំទី ១ និងបានដាក់ចំណោលសម្រាប់ឆ្នាំ ២០២៦ និងឆ្នាំ ២០២៧ ដែលអាចនឹងត្រូវធ្វើការកែតម្រូវតាមការចាំបាច់នៅឆ្នាំបន្ទាប់ ស្របតាមការនិន្នាការប្រែប្រួលនៃបរិការណ៍សេដ្ឋកិច្ចសកល និងតំបន់ ព្រមទាំងស្ថានភាពសេដ្ឋកិច្ច-សង្គមក្នុងប្រទេស។ ជាមួយគ្នានេះ, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ក៏បានកំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗតាមវិស័យ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល, ដែលការកំណត់នេះជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលក្រសួង-ស្ថាប័នត្រូវរៀបចំនាពេលនេះ គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាឱ្យការរៀបចំច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ មានតុល្យភាព និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ខ្លឹមសារស្នូលនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ត្រូវបានគូសរំលេចដូចខាងក្រោម៖

## ២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤-សេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២៥ ត្រូវបានរំពឹងថានឹងងើបវិញបន្តិច ក្នុងរង្វង់ ៣,២% ដែលកើនពី ៣,១% ក្នុងឆ្នាំ ២០២៤ និង ២០២៣ ដោយសារការបន្ថមថយនៃផលប៉ះពាល់ពីវិបត្តិ និងការត្រលប់ជាបណ្តើរៗទៅរកប្រក្រតីភាពនៃអត្រាអតិផរណា ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយរឹតបន្តឹងរូបិយវត្ថុនាពេលកន្លងមក។ ទោះជាយ៉ាងនេះក្តី, សេដ្ឋកិច្ចសកលនៅបន្តហ៊ុមព័ទ្ធដោយហានិភ័យ និង ភាពមិន-ប្រាកដប្រជាខ្ពស់រួមមាន៖ (១). ភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយ/សេដ្ឋកិច្ច ដូចជាការផ្ទុះឡើងនូវជម្លោះនៅតំបន់សមុទ្រក្រហមជាដើម ដែលអាចបន្ទប់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល, (២). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម, (៣). ការងើបវិញនៃថ្លៃទំនិញអន្តរជាតិ ដែលបង្កឡើងដោយភាពតានតឹងភូមិសាស្ត្រនយោបាយ/សេដ្ឋកិច្ច ដែលនឹងអាចជំរុញឱ្យមានការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុឡើងវិញ និង/ឬបន្តអូសបន្លាយយូរជាងការរំពឹងទុក, (៤). និន្នាការកំណើនសេដ្ឋកិច្ចសកលទាប ជាពិសេសកំណើនសេដ្ឋកិច្ចចិន, (៥). ការបន្តកើនសម្ពាធបំណុលសាធារណៈ និង (៦). ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។ លើសពីនេះ, តាមរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចសកលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), កំណើនសេដ្ឋកិច្ចសកលនេះ ស្ថិតក្នុងអត្រាមួយដែលទាបជាងកំណើនសក្តានុពល (Potential Growth) នៅឡើយ ដោយសារវិបត្តិផ្ទួនគួបគ្នា ហើយនឹងមិនអាចវិលទៅរកកម្រិតដែលធ្លាប់មានមុនវិបត្តិជំងឺកូវីដ-១៩ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខឡើយ ដោយហេតុថាវិបត្តិទាំងនេះបានប៉ះពាល់ដល់កត្តាផលិតកម្មសំខាន់ៗរបស់សេដ្ឋកិច្ចរួមមាន៖ កម្លាំងពលកម្ម (Labor Supply), ការវិនិយោគ និងការប្រមូលផ្តុំមូលធន (Investment and Capital Accumulation) និងកត្តាផលិតភាពសរុប (Total Factor Productivity)។

៥-បើទោះបីសេដ្ឋកិច្ចសកលនៅបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់យ៉ាងណាក្តី សេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២៤ នឹងបន្តកើនក្នុងអត្រា ៦,០% ដោយសារការត្រលប់ទៅរកភាពល្អប្រសើរនៃសេដ្ឋកិច្ចសកល ជាពិសេសប្រទេសដៃគូពាណិជ្ជកម្មកម្ពុជា ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកនៅបន្តមានស្ថិរភាពលើចលនការឆ្នាំ ២០២៣ ដែលសម្រេចបានកំណើន ៥% ហើយត្រូវបានចាត់ទុកជាកំណើនមួយខ្ពស់ធៀបនឹងបណ្តាប្រទេសក្នុងតំបន់។ ជារួម, ការពង្រឹងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានា ជាពិសេស

ការពន្លឿនការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និងកម្មវិធីគោលនយោបាយអាទិភាពនានា ជាមួយនឹងការបន្តចលនការកែទម្រង់ស៊ីជម្រៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ទាំងលើការស្តារវិស័យចន្ទល់កំណើនដែលមានស្រាប់ ក៏ដូចជាលើកកម្ពស់វិស័យសក្តានុពលថ្មីៗមួយចំនួនទៀត ដែលរួមមាន ការវិនិយោគលើសហគ្រាសធុនតូចនិងមធ្យម និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលនិងបៃតង នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើនតម្លៃបន្ថែមដល់សេដ្ឋកិច្ចជាតិ។

៦-កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថាស្ថិតក្នុងអត្រា ៦,៣% ក្នុងឆ្នាំ ២០២៥ និង ជាមធ្យម ៦,៦% សម្រាប់ឆ្នាំ ២០២៦-២០២៧, ដែលក្នុងនោះ៖ (១). **វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថាមានកំណើនល្អប្រសើរក្នុងអត្រា ៨,៦% ក្នុងឆ្នាំ ២០២៥ និងក្នុងរង្វង់អត្រា ៩,០% សម្រាប់រយៈពេលមធ្យម ២០២៦-២០២៧ ដែលគាំទ្រដោយអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាបជាងនិន្នាការធម្មតា (មុនវិបត្តិជំងឺកូវីដ-១៩)។ (២). **វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រាប្រមាណ **៥,៦%** ក្នុងឆ្នាំ ២០២៥ និង ប្រមាណ **៥,៧%** សម្រាប់រយៈពេលមធ្យម ២០២៦-២០២៧ ដោយសារការបន្តរក្សាបានចលនការនៃអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារនិងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត ខណៈដែលអនុវិស័យអចលនទ្រព្យនៅបន្តមានកំណើនទាប។ (៣). **វិស័យកសិកម្ម** ត្រូវបានព្យាករថានឹងមានកំណើន ១,១% ក្នុងឆ្នាំ ២០២៥ និង ១,៣% សម្រាប់ ២០២៦-២០២៧ ដោយសារការរំពឹងទុកនូវកំណើនល្អប្រសើរនៃអនុវិស័យដំណាំនិងចិញ្ចឹមសត្វ និងការងើបសន្សឹមៗនៃអនុវិស័យនេសាទ។

៧-ជារួម, សេដ្ឋកិច្ចកម្ពុជា ដែលមានទំហំតូចហើយបើកចំហរ និងមានការផ្សារភ្ជាប់កាន់តែខ្លាំងជាមួយនឹងច្រវាក់ផលិតកម្មក្នុងតំបន់ និងពិភពលោក, សម្រាប់រយៈពេលមធ្យមខាងមុខ ពិសេសសម្រាប់ឆ្នាំ ២០២៥, បាន និងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាដែលបណ្តាលមកពីកត្តាខាងក្រៅរួមមាន៖ (១)-កំណើនថមថយនៃសេដ្ឋកិច្ចសកល និងចិន, (២)-ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល, (៣)-ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ច ដែលអាចបន្ទុចបង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើននៃថ្លៃទំនិញជាអន្តរជាតិ, (៤)-ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម និង (៥)-ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។ ទន្ទឹមនេះដែរ, កម្ពុជាក៏នៅតែបន្តប្រឈមនឹងបញ្ហារចនាសម្ព័ន្ធមួយចំនួននៅក្នុងប្រទេសរួមមាន៖ (១)-ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច, (២)-ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់, (៣)-ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច, (៤)-បរិមាណនិងគុណភាពនៃកម្លាំងពលកម្មជំនាញមិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារ, (៥)-ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម, និង (៦)-ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។

៨-ក្នុងបរិការណ៍នេះ, កិច្ចការកែទម្រង់ជារចនាសម្ព័ន្ធ និងការរៀបចំយន្តការអនុវត្តឱ្យបានច្បាស់លាស់ជាអាទិភាពដ៏ចាំបាច់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុកឱ្យកាន់តែមានសន្ទុះកាន់តែខ្លាំងក្លា និងដើម្បីបញ្ចៀសនូវផលប៉ះពាល់នៃហានិភ័យនានាទាំងកម្រិតសកលនិងតំបន់។ ដូចនេះ, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រមទាំងពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គមឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើអាទិភាពចំនួន ៦ ដូចមានចែងក្នុង **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** រួមមាន៖

- **ការអភិវឌ្ឍមូលធនមនុស្ស** តាមរយៈការពង្រឹងគុណភាពវិស័យអប់រំ, កីឡា, វិទ្យាសាស្ត្រ, និងបច្ចេកវិទ្យា; ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន; ការពង្រឹងប្រព័ន្ធគាំពារសង្គម; និងការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសមធម៌ និងបរិយាប័ន្ន។
- **ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង** តាមរយៈការអភិវឌ្ឍវិស័យនៃប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ; ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទិក, វិស័យថាមពល, វិស័យទឹកស្អាត និងវិស័យឌីជីថល; ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ; ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស, សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរី; និងការធ្វើទំនើបកម្មយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ។
- **ការអភិវឌ្ឍវិស័យឯកជន និងការងារ** តាមរយៈការអភិវឌ្ឍទីផ្សារការងារ; ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាពនិងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ; ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន; ការពង្រឹងការប្រកួតប្រជែង និងយន្តការសេដ្ឋកិច្ចទីផ្សារឱ្យកាន់តែមានប្រសិទ្ធភាព; និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុធនាគារ និងមិនមែនធនាគារ។
- **ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាប័ន្ន** តាមរយៈការធ្វើអតិបរមានីយកម្មផលលាភប្រជាសាស្ត្រ; ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ; ការគ្រប់គ្រងធនធានធម្មជាតិ, វប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព; ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ; ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម; និងការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង។
- **ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល** តាមរយៈការកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថល; ការអភិវឌ្ឍធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, និងប្រព័ន្ធនវានុវត្តន៍ឌីជីថល; ការកសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល; ការកសាងភាពជឿជាក់លើប្រព័ន្ធឌីជីថល; និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។

**៩-អត្រាអតិផរណា** ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងរង្វង់ ២,៧% សម្រាប់ឆ្នាំ ២០២៤ ដោយសារការបន្តងើបវិញនៃសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក, ស្របពេលដែលថ្លៃទំនិញអន្តរជាតិនៅបន្តរក្សាបានស្ថិរភាព។ ក្នុងរយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៥-២០២៧), អត្រាអតិផរណា ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៥% ដោយសារការរក្សាបាននូវចលនការសេដ្ឋកិច្ចក្នុងស្រុក និងប្រក្រតីភាពនៃស្ថានភាព និងថ្លៃទំនិញអន្តរជាតិ។ ទន្ទឹមនេះ, ក្នុងឆ្នាំ ២០២៤, អត្រាប្តូរប្រាក់ផ្លូវការ ត្រូវបានរំពឹងថានឹងធ្លាក់មកត្រឹមប្រមាណ ៤ ០៨៣ រៀល ក្នុងមួយដុល្លារអាម៉េរិក ដោយសារការរំពឹងទុកពីការបន្ធូរបន្ថយនូវការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ គួបផ្សំនឹងវិធានការអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពប្រាក់រៀល។ ក្នុងរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧, អត្រាប្តូរប្រាក់ផ្លូវការ ត្រូវបានរំពឹងថានឹងរក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៦០ រៀល ក្នុងមួយដុល្លារអាម៉េរិក។

**១០-ឱនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) រំពឹងថានឹងត្រលប់ទៅរកនិន្នាការធម្មតាវិញ ពោលគឺមានឱនភាពក្នុងរង្វង់ -១,៥% នៃ ផ.ស.ស. ដោយសារការរំពឹងទុកនូវការងើបវិញនៃការនាំចូលជារួម។ ការនាំចេញក៏រំពឹងថានឹងបន្តងើប និងរក្សាបាននូវចលនការ ដែលនឹងបន្តជំរុញដោយការនាំចេញផលិតផលកម្មន្តសាលមិនមែន

កាត់ដេរ និងការងើបវិញនៃការនាំចេញផលិតផលកាត់ដេរ។ សម្រាប់រយៈពេលមធ្យមខាងមុខ (២០២៥-២០២៧), ឱនភាពគណនីចរន្ត ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រមាណ -៣,៧% នៃផ.ស.ស. ដោយសារការរំពឹងទុកពីការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏នៅបន្តមាននិន្នាការល្អ។ ជាមួយគ្នានេះ, **វំហូរវិនិយោគផ្ទាល់ពីបរទេស** ត្រូវបានរំពឹងថានឹងបន្តកើនដល់ប្រមាណ ៤ ២៥០ លានដុល្លារអាម៉េរិក, សមមូលនឹងប្រមាណ ៩,០% នៃ ផ.ស.ស. ដោយសារការបន្តសកម្មភាពវិនិយោគលើវិស័យសក្តានុពល។ ទន្ទឹមនេះ, ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តកើនក្នុងរង្វង់ ២២ ៣០៣ លានដុល្លារអាម៉េរិក ឬស្មើប្រមាណ ៨,០ ខែ នៃការនាំចូល។ សម្រាប់ឆ្នាំ ២០២៥-២០២៧, វំហូរការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនក្នុងរង្វង់ជាមធ្យមប្រមាណ **៨,៦% នៃ ផ.ស.ស.** ដោយសារការបន្តកើននូវទំនុកចិត្តវិនិយោគ ជាមួយនឹងបរិយាកាសកាន់តែអំណោយផលសម្រាប់ការវិនិយោគនៅកម្ពុជា តាមរយៈការអនុវត្ត **«ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា»** និងគោលនយោបាយគាំទ្រមួយចំនួនទៀត។ ផ្អែកលើមូលដ្ឋាននេះ, ក្នុងរយៈពេលមធ្យមខាងមុខ, កម្ពុជារំពឹងថានឹងអាចទាក់ទាញវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់, ជាពិសេសក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ។ ជាលទ្ធផល, ទុនបម្រុងអន្តរជាតិនឹងបន្តកើន ដោយមានទំហំជាមធ្យមប្រមាណ **៧ ខែ** នៃការនាំចូល។

## ២.២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១១-ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ បានកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, វិធានហិរញ្ញវត្ថុសាធារណៈ និងអាទិភាពគោលនយោបាយ** ដែលមានអធិប្បាយលម្អិត នៅក្នុងឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមនេះ ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជារួម, ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់, **គោលនយោបាយហិរញ្ញវត្ថុសាធារណៈ**សម្រាប់រយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការបន្តអនុវត្ត **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកា (Gradual Fiscal Consolidation Stance)»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម, តាមរយៈការចាប់ផ្តើមកសាងទ្រនាប់ថវិកាឡើងវិញ បន្ទាប់ពីបានអនុវត្តគោលនយោបាយវិស្តារកម្មចំណាយក្នុងការអនុវត្ត វិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ចឆ្នាំ ២០២០-២០២៣ ទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងផ្តោតជាសំខាន់លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការតាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយតម្រង់ទិសធនធានទៅកាន់មុខសញ្ញាចំណាយដែលជាអាទិភាពចំពោះមុខ ពេលគឺចាយវាយឱ្យចំទិសដៅ និងធានាបានតម្លៃនៃលុយ ព្រមជាមួយនឹងការខិតខំពង្រឹងការប្រមូលចំណូលឱ្យបានកាន់តែប្រសើរ ដោយមានការថ្លឹងថ្លែងជាមួយនឹងការបន្តរក្សាឱ្យបាននូវចលនការនិងសន្ទុះនៃសកម្មភាពសេដ្ឋកិច្ច ហើយខិតខំចៀសវាងឱ្យបានជាអតិបរមានូវវិការភាពសេដ្ឋកិច្ច (Economic Distortion)។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការពន្ធដែលមានការកែទម្រង់ស៊ីជម្រៅទៅលើផ្នែករដ្ឋបាល និងទំនើបភាវូបនីយកម្មពន្ធ ក្រោមអភិក្រមមិនបង្កើតបន្ទុកពន្ធថ្មី ដោយថ្លឹងថ្លែងការរក្សាបាននូវចលនការសេដ្ឋកិច្ច និងការបន្តបង្កើនចំណូលសម្រាប់តម្រូវការអភិវឌ្ឍន៍ជាតិ។ ចំណែកឯការកសាងទ្រនាប់ថវិកា នឹងធ្វើឡើងដោយផ្អែកទៅតាមលទ្ធភាពនៃវឌ្ឍនភាពក្នុងការកៀរគរចំណូល និងការធ្វើវិចារណកម្ម និងការបង្កើនប្រសិទ្ធភាពចំណាយ។

ជាមួយនឹងការអនុវត្ត «**ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន**» នេះ, ឱនភាពថវិកាក្នុងរយៈពេលមធ្យមនឹងចាប់ផ្ដើមរួមតូច និងជាសន្សឹមៗ។ ចំពោះផ្នែកចំណូល, រាជរដ្ឋាភិបាលនឹងពង្រីកមូលដ្ឋានចំណូលប្រកបដោយភាពហ្មត់ចត់ និងទន់ភ្លន់ខ្ពស់ ព្រមទាំងបន្តអនុវត្តវិធានការលើកទឹកចិត្តនានារបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ជីវភាពកំណើនសេដ្ឋកិច្ច។ រីឯផ្នែកចំណាយ នឹងត្រូវបានពង្រឹងប្រសិទ្ធភាពប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាឱ្យបាននូវលទ្ធភាពក្នុងការទ្រទ្រង់ចលនការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ព្រមទាំងធានាពុំឱ្យមានការបន្ទុចបង្អាក់ដល់និរន្តរភាពប្រតិបត្តិការការងាររបស់រាជរដ្ឋាភិបាល និងជាពិសេសការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា។

ដូចនេះ, ដើម្បីធានាការសម្រេចបាននូវទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ស្របតាមទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលត្រូវបានដាក់ចេញក្នុង«**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» និង «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិឆ្នាំ ២០២៣-២០២៨**» , «**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧**» កំណត់អាទិភាពគោលនយោបាយសំខាន់ៗ ដូចខាងក្រោម៖

- បន្តការពារសន្តិភាព, ស្ថិរភាពនយោបាយ, សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានា ក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាព និងសុខដុមរមនាប្រជាជន;
- បន្តថែរក្សាសមិទ្ធផលគោលនយោបាយការបរទេស ដោយបន្តអនុវត្តនយោបាយឯករាជ្យ និងកិច្ចសហ-ប្រតិបត្តិការក្នុងតំបន់ និងពិភពលោក;
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងគាំទ្រដល់វិស័យគន្លឹះដែលមានស្រាប់ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ប្រកបដោយចីរភាព, បរិយាប័ន្ន និងភាពធន់;
- ជំរុញការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រដល់ផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់;
- លើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម លើកកម្ពស់វប្បធម៌ និងសុខុមាលភាពប្រជាជន សម្រាប់ការត្រៀមខ្លួនជាប្រជាជននៃប្រទេសចំណូលមធ្យមកម្រិតខ្ពស់;
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យដែលជាប្រភពថ្មីនៃកំណើន គាំទ្រដល់បរិយាកាសប្រកួតប្រជែង និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគដែលបង្កើនតម្លៃបន្ថែមខ្ពស់;
- កសាងជាជំហានៗឆ្ពោះទៅ ការគ្របដណ្តប់សុខភាពជាសកល តាមរយៈការពង្រឹងប្រព័ន្ធសុខាភិបាលជារួម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ, និងបន្តអភិវឌ្ឍប្រព័ន្ធស្បៀង ដែលផ្តល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប;
- បន្តជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ, ទាំងរឹង និងទន់, ដើម្បីបង្កើនផលិតភាព, លើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញពិពិធកម្ម;
- បន្តជំរុញការធ្វើបរិវត្តកម្មឌីជីថល ដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតងដើម្បីកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថលប្រកបដោយចីរភាព;

- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; និង
- បន្តលើកស្ទួយវិស័យឯកជន ដោយគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយមានការបង្កើតបរិយាកាសល្អប្រសើរ តាមរយៈការពង្រឹងការអនុវត្តច្បាប់វិនិយោគថ្មី, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ចជាមួយនឹងភាពប្រកួតប្រជែង និងសមភាព។

## ២.២.១-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧

១២-ផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ព្រមជាមួយនឹងគោលនយោបាយផ្នែកម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានកំណត់ខាងលើ, ពិតានចំណាយគោលតាមវិស័យរយៈពេលមធ្យមឆ្នាំ ២០២៥-២០២៧ ត្រូវបានកំណត់ដូចតទៅ៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៦៤%, ១,៦០%, និង ១,៥៨% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៥, ២០២៦ និង ២០២៧ រៀងគ្នា។
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ២,៧៣%, ២,៦០%, និង ២,៤៩% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៥, ២០២៦ និង ២០២៧ រៀងគ្នា។
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៥,១៧%, ៥,២៦%, និង ៥,៣៨% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៥, ២០២៦ និង ២០២៧ រៀងគ្នា។
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៣,៨៣%, ៣,៨៨%, និង ៣,៩២% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៥, ២០២៦ និង ២០២៧ រៀងគ្នា។

១៣-ក្របខ័ណ្ឌពិតានចំណាយគោលកម្រិតវិស័យនេះ ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងលទ្ធភាពហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី។ ផ្អែកលើមូលដ្ឋាននេះ, ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម) បានកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត** ជូនដល់គ្រប់ក្រសួង-ស្ថាប័ន ចំណែកឯ**ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ** ត្រូវបានកំណត់សម្រាប់ក្រសួង-ស្ថាប័ន ចំនួន ១១ និង**ពិតានចំណាយគោលផ្នែកចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស**ត្រូវបានកំណត់សម្រាប់ក្រសួង-ស្ថាប័ន ចំនួន ១០។ ការកំណត់ពិតានចំណាយគោលដល់កម្រិតក្រសួង-ស្ថាប័ន ធ្វើឡើងដើម្បីពង្រឹងគុណភាពនៃការរៀបចំ **ផែនការយុទ្ធសាស្ត្រថវិកា**, ការបន្តពង្រឹងវិន័យថវិកា, ការបង្កើនប្រសិទ្ធភាពចំណាយ និងការកែលម្អការវិភាជធនធានសាធារណៈជារួម។ ដូចនេះ, **ពិតានចំណាយគោលឆ្នាំ ២០២៥-២០២៧** ផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកាជូនដល់គ្រប់ក្រសួង-ស្ថាប័ន ***ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១*** សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងសម្រាប់ការរៀបចំគម្រោងថវិកាឆ្នាំ ២០២៥ ដែលក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំស្នើឡើង។

### ២.២.២-ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៥

១៤-ក្នុងបរិបទ និងទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៥ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ ២០២៥ ដូចខាងក្រោម៖

### ២.២.២.១-ក្របខ័ណ្ឌចំណូលថវិកាឆ្នាំ ២០២៥

១៥-ចំណូលសរុបថវិការដ្ឋសម្រាប់ឆ្នាំ ២០២៥ គ្រោងសម្រេចឱ្យបាន ១៥,១១% នៃ ផ.ស.ស. ក្នុងនោះ៖

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ១៤,៥២% នៃ ផ.ស.ស. គឺថយចុះ ១,៧៨ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៣,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤។ **ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៤,៨៥% នៃ ផ.ស.ស. គឺថយចុះ ០,៩៤ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៨,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ** ត្រូវគ្រោងសម្រេចឱ្យបាន ៧,៧៨% នៃ ផ.ស.ស. គឺថយចុះ ១,០០ ពិន្ទុភាគរយនៃ ផ.ស.ស. ឬថយចុះ ៤,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ១,៨៩% នៃ ផ.ស.ស. គឺកើន ០,១៦ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើន ១៨,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤។
- **ចំណូលផ្សេងៗ**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន ០,៥៩% នៃ ផ.ស.ស.។
- ចំណែកឯ **ចំណូលផ្សេងៗដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ០,២៧% នៃ ផ.ស.ស. ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,០៣% នៃ ផ.ស.ស.។

ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ, រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកចំណូលមិនមែនសារពើពន្ធ។

### ២.២.២.១.១-ផ្នែកចំណូលពន្ធដារ

១៦-វិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៥ ដើម្បីគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖

- បន្តរៀបចំបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីពង្រឹងការប្រមូលចំណូលពន្ធ,
- បន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធស្របតាមចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រែក្លាយខ្លួនទៅជារដ្ឋបាលសារពើពន្ធទំនើបជំនាន់ ៣.០ (Tax Administration 3.0),
- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាឱ្យវិស័យទាំងនោះក្លាយជាមូលដ្ឋានចំណូលពន្ធបន្ថែម,

- បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព បន្តវិនិយោគនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ព្រមទាំងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យអ្នកបង់ពន្ធងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ,
- បន្តចូលរួមដោយសកម្មក្នុងក្របខ័ណ្ឌក្រុមសិក្សាស្រាវជ្រាវ ឬកិច្ចសហការអន្តរជាតិនានា ក្នុងគោលដៅពិភាក្សា ចែករំលែក និងដកស្រង់បទពិសោធន៍ពីបណ្តាលរដ្ឋបាលសារពើពន្ធ និងស្ថាប័នអន្តរជាតិធំៗនានា ជាពិសេសរដ្ឋបាលសារពើពន្ធអាស៊ីបាស៊ីហ្វិក និងការសិក្សាស្រាវជ្រាវ (SGATAR), ក្រុមការងារគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការពន្ធដារ (BRITACOM) និងវេទិការដ្ឋបាលសារពើពន្ធ ជាដើម,
- បន្តតាមដាន វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា,
- បន្តចរចាជាមួយបណ្តាប្រទេសនានា ព្រមទាំងរដ្ឋសមាជិកអាស៊ាន, អាស៊ានបូក៣ ដែលនៅសេសសល់ លើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា(DTA) ដើម្បីជំរុញកំណើនវិនិយោគពីបរទេស និងបង្កើនមូលដ្ឋានពន្ធ,
- បន្តពង្រឹងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងពង្រឹងមុខងារស្នូលក្នុងការប្រមូលចំណូលពន្ធរួមមាន ការផ្តល់សេវានិងចុះបញ្ជីពន្ធដារ ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្ម និងការតវ៉ា និងតឹងទារបំណុលពន្ធ,
- ពង្រឹងការត្រួតពិនិត្យ និងការធ្វើសវនកម្មចំពោះសហគ្រាសដែលជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងវិស័យដែលមានសក្តានុពលនិងមានហានិភ័យខ្ពស់ ដូចជាវិស័យទូរគមនាគមន៍ អាជីវកម្មរ៉ែ និងការដឹកជញ្ជូនទំនិញ,
- ពង្រឹងយន្តការគ្រប់គ្រងចំណូលពន្ធលើវិស័យផលិតស្រាបៀរ និងភេសជ្ជៈ ស្របតាមសេចក្តីណែនាំលេខ ១៥០២៤ ស្តីពីកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ ដែលតម្រូវឱ្យសហគ្រាសផលិតក្នុងស្រុក ដំឡើងនូវកុងទ័រក្នុងខ្សែច្រវាក់ផលិតកម្ម ដើម្បីវាស់បរិមាណផលិតនៅតាមបំពង់បង្ហូរស្រាបៀ និងអាចទទួលបានទិន្នន័យដោយភ្លាមៗ ពីទីតាំងផលិត,
- ពង្រឹងការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ,
- ពង្រឹងអនុលោមភាពពន្ធលើអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូន,
- អនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់ ស្របតាមគោលនយោបាយថ្មីដែលអនុគ្រោះទំហំដី ដែលជាមូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- ពិនិត្យលទ្ធភាពជំរុញការប្រមូលចំណូលពីវិស័យល្បែងពាណិជ្ជកម្ម (កាស៊ីណូ) ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន,
- រៀបចំប្រព័ន្ធនិងយន្តការដើម្បីអនុវត្តការដំឡើងឧបករណ៍តាមដាន (GPS និង RFID) តាមរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈនិងគ្រឿងសំណង់ និងតាមស្ថានីយ,

- ជំរុញការរៀបចំយន្តការអនុវត្តនិងប្រព័ន្ធគ្រប់គ្រងការកំណត់អត្តសញ្ញាណអចលនទ្រព្យ (Property ID) សម្រាប់អចលនទ្រព្យគម្រោងបុរី,
- បន្តពង្រឹងយន្តការទប់ស្កាត់ការគេចវេះពន្ធ និងកាត់បន្ថយសេដ្ឋកិច្ចស្រមោល ដូចជាការពង្រឹងការចុះបញ្ជីពន្ធដារ, ការធ្វើសវនកម្មពន្ធដារ, ការផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែម, ការចុះអង្កេតសហគ្រាស និងការស៊ើបអង្កេតបទល្មើសពន្ធដារ,
- បន្តរិះរកយន្តការដើម្បីផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែ សាមញ្ញ រហ័ស ងាយស្រួល និងគ្រប់ជ្រុងជ្រោយ ដែលមានលក្ខណៈឌីជីថល និងអនុលោមតាមឧត្តមានុវត្តអន្តរជាតិ,
- ពង្រឹងការអនុវត្តការប្រើប្រាស់តែមប្រឹសម្រាប់បារី តាមរយៈការចុះពិនិត្យការបិទតែមប្រឹលើបារីដែលផ្គត់ផ្គង់ដោយភ្នាក់ងារចែកចាយ ផ្សារទំនើប ហាងលក់ទំនិញ,
- ត្រៀមដាក់ឱ្យអនុវត្តនូវយន្តការបិទតែមប្រឹលើសំបកកេសស្រាបៀរ និងភេសជ្ជៈនានា,
- បន្តពង្រឹងការទារបំណុលពន្ធ និងអនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះបំណុលពន្ធដែលជាអាទិភាពអាចប្រមូលបាន,
- បន្តពង្រឹងការពិនិត្យផ្ទៀងផ្ទាត់ការប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានសុក្រឹតភាពខ្ពស់និងទាន់ពេលវេលា និងពន្លឿនការពិនិត្យឯកសារបង្វិលសង,
- ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ និងផ្លាស់ប្តូរផ្នត់គំនិតមន្ត្រីពន្ធដារ ឱ្យទៅជាអ្នកផ្តល់សេវាកាន់តែល្អជូនអ្នកជាប់ពន្ធ និងអនុវត្តវិធានការដាក់ទោសទណ្ឌចំពោះមន្ត្រីដែលប្រព្រឹត្តខុស។

### ២.២.២.១.២-ផ្នែកចំណូលគយ និងរដ្ឋាករ

១៧-វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២៥ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម៖

- បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការលើកទឹកចិត្តពន្ធនិងអាករជាបន្ទុករបស់រដ្ឋតាមបទប្បញ្ញត្តិជាធរមាន,
- បន្តកែលម្អគោលនយោបាយពន្ធនិងអាករសម្រាប់វិស័យអាទិភាពនានា,
- ធ្វើវិចារណកម្មមុខទំនិញមួយចំនួនដែលពុំមែនជាមុខសញ្ញានៃការលើកទឹកចិត្ត,
- ពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធនិងអាករស្របតាមច្បាប់និងបទប្បញ្ញត្តិថ្មីៗ,
- បន្តកែលម្អនិងពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ និងធ្វើទំនើបកម្មនីតិវិធីគយ តាមរយៈការជំរុញធ្វើឌីជីថលនីយកម្ម,
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេន និងសិក្សាលទ្ធភាពបំពាក់ម៉ាស៊ីនស្កេននៅមាត់ច្រកសំខាន់ៗបន្ថែមទៀត ដើម្បីគាំទ្រការពង្រឹងអនុលោមភាពដោយរក្សាបាននូវកិច្ចសម្រួលពាណិជ្ជកម្ម,

- ជំរុញការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិឱ្យបានពេញលេញ ដោយធ្វើការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យបានសកម្ម និងជំរុញការចេញលិខិតអនុញ្ញាត និងអាជ្ញាបណ្ណនានាតាមប្រព័ន្ធបញ្ជរតែមួយជាតិ,
- ជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត (Authorized Economic Operator - AEO) និងបង្កើនចំនួនក្រុមហ៊ុនទទួលស្គាល់ជា AEO,
- ពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- បន្តកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ តាមរយៈការកែលម្អវិធីសាស្ត្រនិងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ,
- បង្កើនសកម្មភាពត្រួតពិនិត្យអនុលោមភាពនៅដើមទី កណ្តាលទី និងចុងទីបន្ថែមទៀត,
- បង្កើនសកម្មភាពទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធនៅគ្រប់ភូមិសាស្ត្រ និងរៀបចំយន្តការតាមដាន វិភាគ និងវាយតម្លៃហានិភ័យនានា ដែលមានភាពប្រទាក់ក្រឡាគ្នាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកសំណើវិធានការសម្រាប់អនុវត្តតាមស្ថានភាពជាក់ស្តែង,
- ធ្វើសវនកម្មផ្ទៃក្នុងអង្គភាព ដើម្បីធានានូវការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ និងអនុលោមភាពច្បាប់,
- ពង្រឹងវិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និងចាត់វិធានការតឹងរឹងខាងវិន័យតាមច្បាប់ជាធរមានក្នុងករណីប្រព្រឹត្តល្មើស,
- លើកកម្ពស់សមត្ថភាពជំនាញ និងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងជើងសាគយ/ប្រតិវេទករ,
- បន្តពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជនក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហានានា។

### ២.២.២.១.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ

១៨-ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូលពីប្រភពដែលមានសក្តានុពល, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមានៈ

- បន្តជំរុញ និងពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០, ដើម្បីពង្រឹងអភិបាលកិច្ច នៃការគ្រប់គ្រងការកៀរគរចំណូលថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋប្រកបដោយប្រសិទ្ធភាព និងចីរភាព,
- បន្តជំរុញ និងពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨២២/១០ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២, ដើម្បីពង្រឹងអភិបាលកិច្ច នៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាព,

- ជំរុញបញ្ចប់ការរៀបចំផែនការគោលស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងផែនការគោលស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ,
- ពង្រឹងការអនុវត្តកិច្ចសន្យា កិច្ចព្រមព្រៀង ឬ/និងលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធដទៃទៀត,
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងទប់ស្កាត់ការកើតមានបំណុលថ្មី,
- បន្តជំរុញ និងពង្រឹងការអនុវត្តអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០២៣ ស្ដីពីគោលការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ,
- ជំរុញការអនុវត្តប្រកាសអន្តរក្រសួងលេខ ១៣៤ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្ដីពីបែបបទ និងនីតិវិធីនៃការបង់កាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធសម្រាប់ការនាំចេញផលិតផលរ៉ែ,
- បន្តពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីអនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សំដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្ដល់របាយការណ៍ចំណូលមានតម្លាភាព និងទាន់ពេលវេលា,
- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព រួមទាំងការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបង់ចំណូល ការកត់ត្រា និងការតាមដានការប្រមូលចំណូលមិនមែនសារពើពន្ធ,
- បន្តជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីសម្បទានដីសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់ប្រព័ន្ធ NRMIS និងប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment), ការចុះពិនិត្យផ្ទាល់ដល់ទីតាំងឬការដ្ឋានអាជីវកម្មដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រុមការងារអន្តរក្រសួង-ស្ថាប័ន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ការបង់ចំណូល ព្រមទាំងពង្រឹងយន្តការប្រមូលចំណូល និងកិច្ចសហការរវាងក្រសួងជំនាញទទួលបន្ទុក ដើម្បីធានាឱ្យការបង់ចំណូលត្រឹមត្រូវ និងទាន់ពេល។

### ២.២.២.២-ក្របខ័ណ្ឌចំណាយថវិកាឆ្នាំ ២០២៥

១៩-ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យដែលអាចកើតជាយថាហេតុ, គម្រោងចំណាយថវិកាឆ្នាំ ២០២៥ ត្រូវបានកំណត់ និងវិភាជតាមក្របខ័ណ្ឌ ដូចខាងក្រោម៖

- **ចំណាយសរុបថវិការដ្ឋឆ្នាំ** ២០២៥ ត្រូវបានកំណត់ក្នុងរង្វង់ ១៧,៨៤% នៃ ផ.ស.ស. គឺថយចុះ ១,៤៩ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើន ០,៥% ធៀបនឹងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ (ហៅកាត់ថាច្បាប់ថវិកាឆ្នាំ ២០២៤) ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ១៦,៦៥% នៃ ផ.ស.ស. និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,០៣% នៃ ផ.ស.ស. ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៨៤% នៃ ផ.ស.ស.។



៩

- **ចំណាយចរន្តថវិការដ្ឋ** ត្រូវកំណត់ក្នុងកម្រិត ១២,៤១% នៃ ផ.ស.ស. គឺថយចុះ ១,០៧ ពិន្ទុភាគរយ នៃ ផ.ស.ស. ឬកើន ០,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ដែលក្នុងនោះ៖
    - **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៤,៧% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៥,៥៤% នៃ ផ.ស.ស. ដោយផ្តោតអាទិភាពទៅលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការក្នុងគោលដៅរក្សាលំនឹង និងលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,
    - **ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥៥,៣% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៦,៨៧% នៃ ផ.ស.ស. ដោយផ្តោតអាទិភាពទៅលើ៖ (១)-ការពង្រឹងប្រព័ន្ធគាំពារសង្គមដែលមានចរិតចំគោលដៅ ព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា; (២)-រៀបចំមូលដ្ឋានសង្គមកម្ពុជាឱ្យកាន់តែមានភាពធន់រឹងមាំ តាមរយៈការពន្លឿនការកែទម្រង់ក្នុងវិស័យអប់រំ, ការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសជំនាញគ្រប់កម្រិត; និង (៣)-សម្រេចឱ្យបាននូវរាល់គោលដៅអាទិភាពនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- **ចំណាយមូលធន** ត្រូវបានគ្រោងប្រមាណ ៥,៤២% នៃ ផ.ស.ស. គឺថយចុះ ០,៤៣ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើន ១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ក្នុងគោលដៅស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់តាមបទដ្ឋានបច្ចេកទេសកំណត់, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ក៏ដូចជាពង្រឹងមូលដ្ឋានអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេសជំរុញវិស័យដែលជាចន្ទល់កំណើន និងផលិតភាពសេដ្ឋកិច្ច។
- **ចំណាយសរុបថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម៖
    - **ចំណាយវិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៦៤% នៃ ផ.ស.ស. ដើម្បីបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការទូត, ការអនុវត្តច្បាប់ស្តីពីវិនិយោគថ្មី, ការគាំទ្រធុរកិច្ចថ្មី, ថ្នាលឌីជីថល និងសេដ្ឋកិច្ចនវានុវត្តន៍ ព្រមទាំងត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»**, ក៏ដូចជាសម្រាប់ការសងការប្រាក់នៃបំណុលសាធារណៈ និង ការបង្វិលសងអាករលើតម្លៃបន្ថែម។
    - **ចំណាយវិស័យការពារជាតិ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ២,៧៣% នៃ ផ.ស.ស. សំដៅគាំទ្រការកែទម្រង់ប្រព័ន្ធច្បាប់ និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ ក្នុងបុព្វហេតុជានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ។

- ○ **ចំណាយវិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៥,១៧% នៃ ផ.ស.ស. សំដៅបន្តលើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍជំនាញឆ្លើយតបនឹងទីផ្សារ, ពង្រីកវិសាលភាពនៃការទទួលបានសេវា, ថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពសកល និងជំរុញអនុវត្តកម្មវិធីគោលនយោបាយជាតិគាំពារសង្គម និងគោលនយោបាយអាទិភាពផ្សេងទៀតលើផ្នែកសង្គមកិច្ច, សាសនា, វប្បធម៌ និងបរិស្ថាន។
- ○ **ចំណាយវិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៣,៨៣% នៃ ផ.ស.ស. ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដារ និងតម្រូវការទីផ្សារ, ការអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជាឆ្នាំ ២០២២-២០២៧, យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ ២០២៣-២០២៨, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥** និង **គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០** ។ល។
- ○ **ចំណាយផ្សេងៗ** ត្រូវបានគ្រោងប្រមាណ ៣,២៩% នៃ ផ.ស.ស. ដែលជាទំហំមួយសមស្របក្នុងការផ្តល់លទ្ធភាព និងភាពបត់បែនខ្ពស់ដល់រាជរដ្ឋាភិបាល ក្នុងការបំពេញតម្រូវការចំណាយមានមុខសញ្ញា និងការឆ្លើយតបទៅនឹងតម្រូវការចំណាយអាទិភាពណាមួយបានទាន់ពេលក្នុងការដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុងជាដើម។ ដោយឡែក, សម្រាប់ការអនុវត្តជាក់ស្តែង, ចំណាយថវិកាដែលបានគ្រោងក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើ ស្របតាមគោលដៅនៃមុខចំណាយនីមួយៗ។

- **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវកំណត់ត្រឹម ១១,៤៧% នៃ ផ.ស.ស. កើន ០,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ដែលក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៤,៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៥,០៨% នៃ ផ.ស.ស. និង**ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥៥,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៦,៣៨% នៃផ.ស.ស.។
- **ចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិ** ត្រូវកំណត់ត្រឹម ១,៧៩% នៃ ផ.ស.ស. ថយចុះ ១,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៤ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក ០,៤៦% នៃ ផ.ស.ស. និង ចំណាយក្រៅបន្ទុកបុគ្គលិក ១,៣៣% នៃ ផ.ស.ស.។

២០-ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងការងើបវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពថវិកា, ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ, ដោយឈរលើគោលការណ៍គោរពវិន័យថវិកាប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានានៅក្នុងឆ្នាំ ២០២៥ តាមរយៈវិធានការសំខាន់ៗ ដូចខាងក្រោម៖

- បន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ផ្អែកលើមូលដ្ឋាននៃកម្រិតអត្រាអតិផរណា និងសមិទ្ធកម្មការងារ ក្នុងគោលដៅពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, ទាំងគុណភាព និងប្រសិទ្ធភាពរបស់មន្ត្រីរាជការ, ដោយឈរលើគោលការណ៍គុណាធិបតេយ្យ និងចីរភាពថវិកា;
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាពដែលមានគោលការណ៍ដោយឡែករបស់រាជរដ្ឋាភិបាល;
- បន្តអភិវឌ្ឍប្រព័ន្ធអប់រំ និងបង្កើនជំនាញ ស្របតាមតម្រូវការទីផ្សារការងារ និងឌីជីថលភាវូបនីយកម្ម និងពង្រឹងគុណភាពការផ្តល់សេវាសុខាភិបាល រួមទាំងលើកកម្ពស់ប្រព័ន្ធគាំពារសង្គមដើម្បីទ្រទ្រង់ជីវភាពប្រជាជន, ពិសេសគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ;
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់, បរិយាប័ន្ន និងចីរភាពតាមរយៈការផ្តល់អាទិភាពលើការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់រចនាសម្ព័ន្ធ, ការអភិវឌ្ឍមូលធនមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ឌីជីថល, និងបៃតង;
- ការផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការប្រមូលចំណូល ដើម្បីរក្សាតុល្យភាព និងចីរភាពថវិកា តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ និងពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ពិនិត្យ និងវាយតម្លៃហានិភ័យឱ្យបានហ្មត់ចត់ លើការអនុវត្តគម្រោងវិនិយោគសាធារណៈនីមួយៗ ដើម្បី អាចគ្រប់គ្រងលើហានិភ័យដែលអាចកើតមានឡើង និងកាត់បន្ថយចំណាយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការអនុវត្តថវិកា;
- ពង្រឹងការតាមដាន និងវាយតម្លៃលើការអនុវត្តថវិកា និងការផ្សារភ្ជាប់ថវិកាទៅនឹងសមិទ្ធកម្ម ដើម្បីធានាឱ្យបាននូវតម្លាភាព និងប្រសិទ្ធភាពថវិកា;
- បន្តរក្សាចីរភាពបំណុលរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប តាមរយៈការកំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ, កំណត់សូចនាករបំណុលគន្លឹះសំខាន់ៗ, កំណត់គោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទាន និងធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ; និង
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព, ជាពិសេសវិស័យបង្កើនផលិតភាព និងតម្លៃបន្ថែម, ជំរុញការតភ្ជាប់, ពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច។

### ២.២.២.៣-ក្របខ័ណ្ឌតុល្យភាពថវិកាឆ្នាំ ២០២៥

២១-ជារួម ការអនុវត្តនូវវិធានការផ្នែកចំណូល និងផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ២,១០% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ -២,៧៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៥ ក្នុងគោលដៅ, ម្យ៉ាង, **ខាងផ្នែកចំណាយចរន្ត** គឺបន្តបង្កើនបៀវត្សអប្បបរមាជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរក្សានិរន្តរភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន និងបន្តធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិ ជំនួយសង្គម និង ម្យ៉ាងទៀត, **ខាងផ្នែកចំណាយវិនិយោគ** គឺគិតគូរពីតម្រូវការចំណាយសម្រាប់ការអភិវឌ្ឍ, រក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, លើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរនូវបរិយាកាស

ធុរកិច្ច ពោលគឺរាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ពិសេសតាមរយៈ ១)-ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានគុណភាពខ្ពស់តាមបទដ្ឋានបច្ចេកទេសកំណត់ និង ២)-ការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម កសាងភាពធន់នៃសង្គមកម្ពុជា និងធានាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗដែលមានចែងក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា។

## ៣-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧

២២-ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ជាពិសេសពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័ននីមួយៗដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនឱ្យបានល្អត្រឹមត្រូវតាមគោលដៅនេះ។ គួរកត់សម្គាល់ផងដែរថា ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្ដីសំអាងអំពីតម្រូវការថវិកាសម្រាប់ការងារអាទិភាព និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

២៣-ដូចនេះ, ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលត្រូវគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដោយត្រូវធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ, ដើម្បីធានាបាននូវផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព និងភាពគ្រប់ជ្រុងជ្រោយ, *ក្រសួង-ស្ថាប័ននីមួយៗ ត្រូវជំរុញ និងលើកទឹកចិត្តដល់* ***ក្រុមការងារថវិកា*** *របស់ខ្លួនដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ឬ/និង ថវិកា/គណនេយ្យ ដែលហៅថា* ***"អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ"****, អគ្គនាយកដ្ឋាន/នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោងឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួល-ខុសត្រូវខ្ពស់។*

២៤-ក្នុងន័យនេះ ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថា ថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងៗខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណង គោលនយោបាយ និងវាងកម្មវិធីដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ដូចនេះ, ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ ឱ្យមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ, ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន តាមទម្រង់ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ២។

២៥-ផ្អែកលើកញ្ចប់ថវិកាក្នុង**កម្រិតពិតានចំណាយគោល** ដែលត្រូវបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន ដូចមានលម្អិតក្នុងផ្នែក ២.២ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ, **ក្រសួង-ស្ថាប័នត្រូវធ្វើផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ) ដោយត្រូវគោរពតាមពិតានចំណាយគោលដែលបានផ្តល់ជូនសម្រាប់សកម្មភាពការងារ ឬគម្រោង ដែលត្រូវបន្តអនុវត្តក្នុងក្របខ័ណ្ឌដែលមិនមានការផ្លាស់ប្តូរខាងអាទិភាពគោលនយោបាយ។ ជាមួយគ្នានេះ, ក្រសួង-ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីៗ ដែលទើបមានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។**

២៦-ជាមួយគ្នានេះដែរ, ក្រសួង-ស្ថាប័ន ត្រូវកំណត់ **អង្គភាពទទួលខុសត្រូវ** ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រង ទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) ឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានបន្ទាត់គណនេយ្យភាព ដែលមានការទទួលខុសច្បាស់លាស់ក្នុងការគ្រប់គ្រង និងអនុវត្តថវិកា។ ទន្ទឹមនេះ, ដើម្បីពង្រឹងការអនុវត្ត *អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា*ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់, នៅក្នុងអំឡុងនៃការរៀបចំគម្រោងថវិកាឆ្នាំ ២០២៥ នេះ *ក្រសួង-ស្ថាប័ន ត្រូវដាក់ចេញនូវផែនការច្បាស់លាស់ ក្នុងការបង្កើនចំនួនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញសម្រាប់ការអនុវត្តនៅឆ្នាំ ២០២៥, ឆ្នាំ ២០២៦ និងឆ្នាំ ២០២៧*។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្តល់កិច្ចសហការ ផ្នែកបច្ចេកទេសលើការពិនិត្យ និងវាយតម្លៃអំពីលក្ខណៈវិនិច្ឆ័យរបស់អង្គភាពដែលអាចនឹងត្រូវបង្កើតជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ឬអង្គភាពថវិកាដែលអាចនឹងប្រែក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពផ្នែកថវិកា និងនីតិវិធីហិរញ្ញវត្ថុ ដល់អង្គភាពថវិកា តាមការស្នើសុំពីក្រសួង-ស្ថាប័នសាមីនីមួយៗ។

## ៣.១-ការគ្រោងចំណូលថវិកាសម្រាប់ឆ្នាំ ២០២៥-២០២៧

២៧-ការគ្រោងចំណូល គឺត្រូវគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៥-២០២៧ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត។ ក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចខាងក្រោម៖

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញនៅក្នុងសារាចរនេះ ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម**តារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ**។ នៅក្នុងផ្នែកនេះ, ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។



ß

ទន្ទឹមនេះ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ, ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយនៅក្នុងកិច្ចប្រជុំចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

## ៣.២-ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៥-២០២៧

២៨-ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៥-២០២៧ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន ទាំងថវិកាជាតិ និងទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ។**

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយ ទាំងផ្នែកចំណាយចរន្ត និងចំណាយមូលធន (ឬហៅថាចំណាយវិនិយោគ)។ ក្នុងន័យនេះ, ***ពិតានចំណាយគោល, ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១, ត្រូវបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៥-២០២៧)*** សម្រាប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) សម្រាប់ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០២៥-២០២៧ និងការរៀបចំគម្រោងថវិកាឆ្នាំ ២០២៥។

ទី២-ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២៤ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពតាមតម្រូវការដាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើ**ទិដ្ឋភាព ៣** គឺ៖

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។

ដូច្នេះ, ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ, គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មាន

ភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០២៥-២០២៧ តាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា ដូចខាងក្រោម៖

• **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)៖ រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា បន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់ដល់ការរក្សាលំនឹង និងលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែប្រសើរ។ ដូចនេះ, **សម្រាប់ឆ្នាំ ២០២៥** ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមគោលការណ៍ណែនាំលម្អិត, សម្រាប់ការជ្រើសរើសចំនួនក្របខ័ណ្ឌថ្មី និងការដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ, និងសម្រាប់ការកំណត់ចំនួន និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងសម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យភ្ជុំបិណ្ឌ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន, ដែលមានចែងក្នុង**ចំណុច (ក) នៃផ្នែក ៤.២-អំពីការគ្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៥**។ ដោយឡែក, សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៦ និងឆ្នាំ ២០២៧ ត្រូវគ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០២៥ និងឆ្នាំ ២០២៦ រៀងៗគ្នា ហើយចំនួនក្របខ័ណ្ឌថ្មី យ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ និងផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រសួងមុខងារសាធារណៈ។

• **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៥-២០២៧ ប៉ុន្តែ កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការវិភាជថវិកា និងប្រតិបត្តិការចំណាយ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នត្រូវកាត់ចេញចំណាយលើមុខសញ្ញាការងារ ឬសកម្មភាពដែលបញ្ចប់ក្នុងឆ្នាំ ២០២៤ ឬចំណាយមិនប្រចាំដែលមិនចាំបាច់ លែងចាំបាច់ ដើម្បីរក្សាលំហថវិកា សម្រាប់គម្រោង ឬកម្មវិធីចំណាយថ្មីដែលទើបមានការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងឆ្នាំអនុវត្តថវិកានេះ។ ទន្ទឹមនេះ, រាល់ការគ្រោងចំណាយទាំងអស់ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមាន៖ ការសិក្សា, វិភាគ, វាយតម្លៃ និងការផ្តល់អំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃទំហំពិតានចំណាយគោល។ **ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលទទួលបាននូវការប្រគល់មុខងារពីក្រសួងសុខាភិបាល** ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ សម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក, សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ, ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានគ្រោងផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន សម្រាប់រយៈពេល ៣ ឆ្នាំ (ឆ្នាំ ២០២៥-២០២៧) **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និង ម្យ៉ាងទៀត, ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក ២១)៖ ត្រូវបានផ្តល់ពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ១១ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្រសួងទាំង ១១ ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២៥-២០២៧ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី និងដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ទោះយ៉ាងនេះក្តី, ក្រសួងទាំង ១១ ខាងលើនេះ នឹងមិនទទួលបានកញ្ចប់ចំណាយវិនិយោគជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូបនីយកម្មគម្រោង និងការផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង។ ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ក៏ត្រូវចាប់ផ្តើមសិក្សារៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ឱ្យច្បាស់លាស់ និងរៀបចំលើកសំណើគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំធ្វើអាទិភាវូបនីយកម្មគម្រោងតាមការចាំបាច់ ហើយគោរពស្នើសុំប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចតាមលទ្ធភាពថវិកា និងតាមវិធានការផ្អែកចំណាយដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរនេះ។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ៖** ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ១០ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ចំពោះក្រសួង-ស្ថាប័នដទៃទៀត ដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៥-២០២៧) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

## ៤-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២៥

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងចំណូល-ចំណាយ ដូចខាងក្រោម៖



ៗ

### ៤.១-ការគ្រោងចំណូលថវិកាឆ្នាំ ២០២៥

២៩-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួន ដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ ២០២៤);
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ;
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ;
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

### ៤.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២៥

៣០-ថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា "ថវិកាសមិទ្ធកម្ម" ព្រមជាមួយនឹងការរៀបចំនូវកិច្ចព្រម-ព្រៀងសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០២៣។ ដូចនេះ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្ដោតការយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងលើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងត្រូវសម្រេចបាន។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នត្រូវពង្រឹងបន្ថែមនូវប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពិភាក្សា ចរចាថវិកា ក៏ដូចជាសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ, ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ, ម្យ៉ាង, ដើម្បីសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ និងម្យ៉ាងទៀត, ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អផងដែរ។ ជាមួយគ្នានេះ, *ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការកំណត់គោលបំណង និងកត្តាកំណត់ជោគជ័យនៃកម្មវិធី និងអនុកម្មវិធី ឱ្យបានល្អ ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយពិសេសត្រូវកំណត់សូចនាករគន្លឹះ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។*

៣១-ការរៀបចំផែនការសមិទ្ធកម្ម៖ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការសមិទ្ធកម្ម (សូចនាករគន្លឹះ និងគោលដៅសូចនាករ) ប្រចាំឆ្នាំ ទៅតាមកម្មវិធី និងអនុកម្មវិធីនីមួយៗ តាមទម្រង់ ដូចមានភ្ជាប់ជូនក្នុង *តារាង ក* ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុប ជាឯកសារឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ សម្រាប់ដាក់ឆ្លងការពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ព្រមទាំងសម្រាប់ជាកម្មវត្ថុនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន ត្រូវផ្ញើ **ផែនការសមិទ្ធកម្ម ដោយភ្ជាប់មកជាមួយនឹងគម្រោងថវិកាឆ្នាំ ២០២៥ របស់ខ្លួន** មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (*អគ្គនាយកដ្ឋានថវិកា*) តាមកាលបរិច្ឆេទកំណត់ក្នុងសារាចរនេះ។

៣២-កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានកំណត់ជា ៣ កម្រិត៖ *(ទី១)-រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នសាមី, (ទី២)-រវាងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង-ស្ថាប័នសាមី, និង (ទី៣)-រវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា* ***ដូចមានភ្ជាប់ជូននូវគំរូកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង ៣ កម្រិតនេះ។ សម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៥ ខាងមុខ នេះ, គ្រប់ក្រសួង-ស្ថាប័នទាំងអស់ត្រូវបានកំណត់ឱ្យអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ។***

៣៣-**គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យ អប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះ, ការគណនាតម្រូវការចំណាយត្រូវផ្អែកលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០២៣ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២៤ និងដោយផ្អែកលើថ្លៃឯកតានៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

៣៤-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មានក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ ក្នុងកម្រិតនៃទំហំពិតានចំណាយគោលដែលបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), **ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០២៥ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយរបស់ខ្លួនទៅតាមគោលការណ៍ និងបណ្តាវិធានការ ដូចខាងក្រោម៖**

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)៖** នាយកដ្ឋានបុគ្គលិក/អង្គភាពគ្រប់គ្រងធនធានមនុស្ស ដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងន័យនេះ, ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២៥ ត្រូវអនុវត្តនូវគោលការណ៍លម្អិត ដូចខាងក្រោម៖

- **ចំនួនក្របខ័ណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ក្នុងឆ្នាំ ២០២៤ និងដោយផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រសួងមុខងារសាធារណៈ។ ទន្ទឹមនេះ,

មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលចូលបម្រើការងារវិញ ក៏ជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ។ លើសពីនេះ, *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី មានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍លាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព, ក្រសួង-ស្ថាប័នអាចស្នើសុំប្រើប្រាស់ថវិកានោះ ដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រី ដែលមានគុណវុឌ្ឍិ និងសមត្ថភាពជំនាញខ្ពស់ និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួនពិសេស សម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗ របស់ក្រសួង-ស្ថាប័ន។*

- **សន្ទស្សន៍បៀវត្សមូលដ្ឋាន** ត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២៤ (តម្លៃសន្ទស្សន៍ក្នុង ១ ឯកតាស្មើនឹង ២ ៦៣០ រៀល)។ ដោយឡែកចំពោះ **ប្រាក់បំណាច់មុខងារ** ត្រូវគ្រោងដំឡើងចំនួន **៤០ ០០០ រៀល ដើម្បីរក្សាលំនឹង និងលើកកម្ពស់ជីវភាពជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ** ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។
- គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន **៥ ម៉ឺនរៀល** ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន **៥ ម៉ឺនរៀល ក្នុងម្នាក់** ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង
- គ្រោងចំនួនមន្ត្រីជាប់កិច្ចសន្យាមិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២៤ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះមន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោង**ដំឡើងពី ៧៧ ម៉ឺនរៀល ទៅដល់ ៧៩ ម៉ឺនរៀល** ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។

ជាមួយគ្នានេះ, សម្រាប់ឆ្នាំ ២០២៥, រាជរដ្ឋាភិបាលបានត្រៀមបម្រុងកញ្ចប់ថវិកាដោយឡែកផងដែរសម្រាប់ដំឡើងប្រាក់សោធនក្នុងកម្រិតអត្រាអតិផរណា ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដើម្បីជួយទ្រទ្រង់ជីវភាពឱ្យបានសមរម្យ ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។ គោលការណ៍លម្អិតសម្រាប់អនុវត្តនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖** *គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវបានផ្តល់ការលើកទឹកចិត្តឱ្យធ្វើការកែលម្អមុខសញ្ញាចំណាយចាស់ៗ ដោយលុបចោល មុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ដើម្បីបង្កើតមុខសញ្ញាចំណាយថ្មី ឬសកម្មភាពថ្មី ដែលបម្រើឱ្យកម្មវិធីកែទម្រង់ថ្មីៗ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងទ្រទ្រង់វិស័យចន្ទល់កំណើនសេដ្ឋកិច្ចដែលមានស្រាប់ និងបង្កើតវិស័យចន្ទល់កំណើនសេដ្ឋកិច្ចថ្មីៗ។* ដូចនេះ, ក្រសួង-ស្ថាប័ន មន្ទីរ-ជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ ដូចខាងក្រោម៖

- *កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ចំណាយលើសម្ភារផ្គត់ផ្គង់ និងថែទាំជាប្រចាំ (ដូចជា៖ សម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារ ការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដែលអនុវត្តផ្ទាល់**។

- *កំណត់ចំណាយមិនប្រចាំ ដោយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យច្បាស់លាស់*។ ចំណាយមិនជាប្រចាំ គឺជាចំណាយដែលមិនត្រូវការចំណាយជារៀងរាល់ឆ្នាំ រួមមាន៖ ចំណាយបំពាក់ឧបករណ៍ សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយនេះ ត្រូវមានគម្រោង និងពេលអនុវត្តច្បាស់លាស់សម្រាប់ទាំងពេលខ្លី និងពេលមធ្យម ព្រមទាំងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែង។

- ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖ ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៥ ប៉ុន្តែ*កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ*។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ នេះមានន័យថា ពិតានចំណាយគោល គឺនៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សានៅពេលចរចាថវិកា ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មី។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២៥ មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវគ្រោងថវិកាចំណាយយ៉ាងច្រើនបំផុតស្មើនឹងកម្រិតអតិបរមានៃទំហំពិតានចំណាយគោល។ **ក៏ប៉ុន្តែ *កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ* នឹងមិនទទួលបាន**ជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទបញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២៣ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២៤ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ, ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ, *ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោង ចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍*។ កិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេនគឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលាដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តក្នុងឆ្នាំ ២០២៤ ហើយលែងត្រូវការក្នុងឆ្នាំ ២០២៥ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៤។ លើសពីនេះ, ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថា លែងមានសារៈសំខាន់ ដូចជា៖ សកម្មភាពចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្ម និងពិព័រណ៍ទេសចរមួយចំនួនដែលលែងមានភាពចាំបាច់។ ក្នុងន័យនេះ, ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងមានយុត្តការណ៍អំពីភាពចាំបាច់ និងបន្ទាន់ ព្រមទាំងមានការពន្យល់ និងផ្តល់អំណះអំណាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីកញ្ចប់ថវិកា ដែលត្រូវបានកំណត់ជាពិតានចំណាយគោល គឺត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។

- *សម្រាប់ក្រសួង-ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានការកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែង បន្ថែមសម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូលព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។ ទន្ទឹមនេះ, ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរពិចារណាដាក់បញ្ចូលទៅក្នុងគម្រោងថវិកានូវបណ្តាអាទិភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចមានចែងនៅក្នុងផែនការស្តីពីការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (២០២០) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមលទ្ធភាពថវិកាជាក់ស្តែង។

- **ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗឱ្យអស់លទ្ធភាព** ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាចទៅតាម និងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុងក្រសួង-ស្ថាប័ន** មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំង**រដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មីនៅក្នុងក្រសួង-ស្ថាប័នដដែល ឬទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញមួយ ទៅមន្ទីរជំនាញមួយទៀតនៃ**ក្រសួង-ស្ថាប័នតែមួយ ក៏ដូចជាពីមន្ទីរនៃរដ្ឋបាលថ្នាក់ក្រោមជាតិមួយ ទៅមន្ទីរនៃរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀត**ក្នុងក្របខ័ណ្ឌនៃវិស័យចំណាយតែមួយ។

**គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១) និងចំណាយជួសជុលនិងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១)** ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាននិងកំពុងអនុវត្តជាធរមាន និងស្របតាមគោលការណ៍ដូចខាងក្រោម៖

- ក្នុងចំណោមក្រសួងទាំង ១១ ក្នុងនោះក្រសួងចំនួន ៧ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ក្រសួងទាំង ៧ នេះ ត្រូវរៀបចំបញ្ជីគម្រោង



ៗ

អាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេល ដើម្បីស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាលជាមុន សម្រាប់ជាមូលដ្ឋាននៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ចំពោះក្រសួង ៤ ទៀតមានដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ត្រូវចាប់ផ្តើមសាកល្បងធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធី និងអនុកម្មវិធីផងដែរ។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោងដែលមានចែងនៅក្នុងសារាចរនេះ សម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

- សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងរៀបចំអាទិភាវូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- ការគ្រោងចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ផ្លូវថ្នល់ និងធារាសាស្ត្រ) ត្រូវបន្តអនុវត្តតាមគោលការណ៍កំណត់អាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- **<u>វិស័យផ្លូវថ្នល់</u>**
  - ✓ **អាទិភាពទី ១៖** គម្រោងថែទាំ ជួសជុល ស្តារ និងលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ តាមសមត្ថកិច្ចទទួលខុសត្រូវរៀងៗខ្លួន ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព ជានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ និងទ្រទ្រង់កំណើន សេដ្ឋកិច្ច។
  - ✓ **អាទិភាពទី ២៖** គម្រោងថ្មីដែលមានការសម្រេចពី **ប្រមុខរាជរដ្ឋាភិបាល**។
  - ✓ **អាទិភាពទី ៣៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់។ ក្នុងករណីចាំបាច់ ត្រូវពិនិត្យវាយតម្លៃឡើងវិញនូវប្រសិទ្ធភាព និងអត្ថប្រយោជន៍នៃគម្រោង។
  - ✓ **អាទិភាពទី ៤៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។
- **<u>វិស័យធារាសាស្ត្រ</u>**
  - ✓ **អាទិភាពទី ១៖** គម្រោងថែទាំ ជួសជុល ស្តារ និងលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព, ជានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
  - ✓ **អាទិភាពទី ២៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់ ដើម្បីបង្គ្រប់ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម។
  - ✓ **អាទិភាពទី ៣៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។
- **<u>វិស័យអប់រំ</u>**
  - ✓ **អាទិភាពទី ១៖** គម្រោងដែលមានការសម្រេចច្បាស់លាស់ពីប្រមុខរាជរដ្ឋាភិបាល។

- ✓ **អាទិភាពទី ២៖** គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ ដែលគាំទ្រដល់ការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកែលម្អការលើកកម្ពស់វិស័យអប់រំ ជាពិសេសសាងសង់អគារសិក្សា ដោយឈរលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃច្បាស់លាស់អំពីតម្រូវការជាអាទិភាព។

- <u>វិស័យសុខាភិបាល</u>
  - ✓ **អាទិភាពទី ១៖** គម្រោងជួសជុល សាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល និងបរិក្ខារពេទ្យ ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព និងធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់។
  - ✓ **អាទិភាពទី ២៖** គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ជាពិសេសការសាងសង់មន្ទីរពេទ្យ, មណ្ឌលសុខភាព និងការបំពាក់បរិក្ខារពេទ្យតាមមូលដ្ឋានសុខាភិបាល សំដៅគាំទ្រការអនុវត្តផែនការគន្លឹះរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកែលម្អការលើកកម្ពស់វិស័យសុខាភិបាល ដោយឈរលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃច្បាស់លាស់អំពីតម្រូវការជាអាទិភាព។
- <u>វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ</u>
  - ✓ **អាទិភាពទី ១៖** គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់។
  - ✓ **អាទិភាពទី ២៖** គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលការពារព្រំដែន។
  - ✓ **អាទិភាពទី ៣៖** គម្រោងជួសជុលនិងស្ថាបនាពន្ធនាគារ។
- <u>វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>
  - ✓ **អាទិភាពទី ១៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់ ដើម្បីបង្គ្រប់ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម។
  - ✓ **អាទិភាពទី ២៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ចំពោះវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈច្បាស់លាស់។

**ឃ-ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ៖** ក្រសួង-ស្ថាប័នចំនួន ១០ ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) និងថវិកាជំពូក ៦១ (ការជួសជុល និងថែទាំ) ព្រមទាំងក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៥-២០២៧) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

**៣៥-ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែ មករា នៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែល

ត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២៥ របស់ខ្លួនចំនួន**ពីរច្បាប់** (១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ១ ច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក, ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

**៣៦-ការរៀបចំផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន៖** ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថា ឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកា ដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

**៣៧-ការផ្តល់របាយការណ៍សមិទ្ធកម្ម៖** ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០២៣ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២៥ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២៣ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២៤ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២៥។*

ទន្ទឹមគ្នានេះ, សម្រាប់ការអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម និងស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម, គ្រប់ក្រសួង-ស្ថាប័ន ត្រូវចាប់ផ្តើមរៀបចំរបាយការណ៍ចំណាយបន្ទុកបុគ្គលិកដោយបែងចែកទៅតាមកម្មវិធីនីមួយៗ ទៅតាមទម្រង់តារាង**លេខ ១១** ដូចមានភ្ជាប់ជូន ដោយយកឆ្នាំនៃការអនុវត្តថវិកា ១ ឆ្នាំមុន (ឆ្នាំ N-1) ជាមូលដ្ឋានសម្រាប់ការរៀបចំ។

**៣៨-ការបម្រែបម្រួលនៃការគ្រោងថវិកាតាមកម្មវិធី៖** ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២៤ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២៥, ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្តដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យឥណទានដើមឆ្នាំរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

៣៩-អនុវត្តតាមប្រកាសលេខ ៣៥៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០២២ **ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិការគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង**, នៅឆ្នាំ ២០២៤ នេះ, ក្រសួង-ស្ថាប័នចំនួន ៤ រួមមាន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ), ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានជ្រើសរើសឱ្យអនុវត្តសាកល្បងនូវគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។ សម្រាប់ការគ្រោងថវិកាឆ្នាំ ២០២៥, ក្រសួង-ស្ថាប័នចំនួន ១០ រួមមាន៖ ក្រសួងធម្មការ និងសាសនា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងរ៉ែ និងថាមពល, ក្រសួងទេសចរណ៍, ក្រសួងអភិវឌ្ឍន៍ជនបទ, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងការពារជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានជ្រើសរើសបន្ថែមសម្រាប់ការអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង ដោយតម្រូវឱ្យផ្លាស់ប្តូរការគ្រោងថវិការបស់ខ្លួនលើមុខចំណាយជាសារវន្តមួយចំនួន (ឧ. ចំណាយទិញរថយន្ត និងចំណាយទិញទោចក្រយានយន្ត) ដែលមានចរិតជាចំណាយមូលធន ដោយប្តូរពីការគ្រោងក្នុងជំពូក ៦០ និងជំពូក ៦១ នៃថវិកាចំណាយចរន្ត ទៅគ្រោងក្នុងជំពូក ២០, ជំពូក ២១ ឬជំពូក ២៣ នៃចំណាយមូលធនវិញ ស្របតាមវិធីសាស្ត្រដែលមានចែងលម្អិតក្នុងគោលការណ៍ណែនាំនេះ។

៤០-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ៤.៣- កាលវសាននៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៥

៤១-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥។ ក្នុងកិច្ចដំណើរការនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវដឹកនាំការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ នេះ ដើម្បីសេចក្តីព្រាងច្បាប់នេះ និងសំណុំឯកសារពាក់ព័ន្ធ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ឱ្យបានចប់សព្វគ្រប់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ស្របតាម មាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថ្មី។ ដូចនេះ, **ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៥-២០២៧ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៥** ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង

គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដាក់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។

ក្នុងន័យនេះ, ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូ ដែលភ្ជាប់ជាមួយសារាចរនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេល ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។

## ៥- សេចក្តីសន្និដ្ឋាន

៤២-ខ្លឹមសារនៃសារាចរនេះ បានកំណត់ក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅធានាសម្រេចឱ្យបានជោគជ័យនូវគោលបំណងគោលនយោបាយ និងកម្មវិធី ដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ, ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាបាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់, ដោយសារកំណើនថមថយនៃសេដ្ឋកិច្ចសកលនិងចិន ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ចដែលអាចបន្ធច់បង្អាក់ដល់ប្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងវិធានការចាំបាច់និងបន្ទាន់នានាក្នុងគោលដៅលើកកម្ពស់ការកសាង មូលដ្ឋានគ្រឹះសេដ្ឋកិច្ច ក៏ដូចជាពង្រឹង និងពង្រីកសសរស្តម្ភសេដ្ឋកិច្ចជាតិឱ្យមានជីវភាព ភាពចម្រុះ ភាពរឹងមាំ និង ភាពធន់។

៤៣-ទោះជាយ៉ាងណាក្តី, ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរផ្តាច់ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទ និងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរនេះ។ ទន្ទឹមនេះ, គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៤៤-ពេលទទួលបានសារាចរនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាការប្រញាប់នូវ *ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២៥-២០២៧ ដែលមានវិសាលភាពគ្របដណ្ដប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), និងគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥* ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០២៤ ជាកំហិត** ដើម្បីមានពេលគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងអាចចាប់ផ្ដើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័នបានទាន់ពេលកំណត់។ ក្នុងការអនុវត្តសារាចរនេះ, ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)។

ថ្ងៃចន្ទ ៦ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
- គ្រប់គណៈអភិបាលក្រុង-ស្រុក
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ